## រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# ទស្សនទានអំពីកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការនៅកម្ពុជា

*ខែវិច្ឆិកា ឆ្នាំ២០១៦*

# មាតិកា

១. សេចក្តីផ្តើម
២. អភិបាលកិច្ចតាមបែបវិមជ្ឈការ
៣. វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា
៤. ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
៥. ការរៀបចំឡើងវិញប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
៦. ទំនាក់ទំនងរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

# ១. សេចក្តីផ្តើម



សង្គមរាស្ត្រនិយម



ប៉ុល ពត ១៩៧៥-៧៩




- បោះឆ្នោតជាតិលើកទី១(១៩៩៣)
- ព្រះរាជាណាចក្រកម្ពុជា



បោះឆ្នោតឃុំ សង្កាត់ លើកទី១(២០០២)

ទសវត្សរ៍៦០ ៧០ ៨០ ៩០ ២០០០ ២០១០




លន់ នល់ ១៩៧០-៧៥



ក្រោយថ្ងៃ៧ មករា ១៩៧៩៖
- សាធារណរដ្ឋប្រជាមានិតកម្ពុជា
- រដ្ឋកម្ពុជា



សន្តិភាពពេញលេញ ចុងឆ្នាំ១៩៩៨

សង្គ្រាមស៊ីវិលរ៉ាំរ៉ៃ

នយោបាយឈ្នះ-ឈ្នះ

# ២. អភិបាលកិច្ចតាមបែបវិមជ្ឈការ

❖ វិមជ្ឈការលើពិភពលោក ៖

| ទសវត្សរ៍ | ៦០ | ៨០ | ៩០ | ចុង៩០ |
|---|---|---|---|---|
| ប្រទេស | • ណេប៉ាល់<br>• តាន់ហ្សានីយ៉ា | • អាមេរិចឡាទីន ៖ Bolivia, Brazil, Chile, Colombia, Guatemala, Haiti Jamaica, Nicaragua និង Mexico<br>• អាហ្វ្រិក ៖ Cameroon, Uganda និង Maldives<br>• អាស៊ីខាងត្បូង ៖ Nepal និង Sri Lanka<br>• អាស៊ីខាងកើត ៖ Vietnam | បណ្តាប្រទេសអឺរ៉ុបខាងកើត | រីកសាយភាយទៅដល់ប្រទេសភាគច្រើននៅលើពិភពលោក |

# ២. អភិបាលកិច្ចតាមបែបវិមជ្ឈការ (ត)

❖ មូលហេតុដែលប្រទេសជាច្រើនចាប់អារម្មណ៍វិមជ្ឈការ ៖

- កត្តានយោបាយ
- ភូមិសាស្ត្រ
- ប្រជាសាស្ត្រ
- សេដ្ឋកិច្ច វប្បធម៌
- ប្រពៃណី
- ដោះស្រាយបញ្ហាភាពក្រីក្រ
- វិសមភាពយេនឌ័រ
- បញ្ហាបរិស្ថាន និង
- ការលើកកម្ពស់ការថែទាំសុខភាព អប់រំ និងការទទួលបានបច្ចេកវិទ្យា
- ការលើកកម្ពស់ការចូលរួមពីអ្នកពាក់ព័ន្ធនានា

# ២. អភិបាលកិច្ចតាមបែបវិមជ្ឈការ (ត)




*វិមជ្ឈការ ក្នុងបរិបទទូទៅ៖*

- ជាដំណើរការមួយ ដែលសិទ្ធិ អំណាច និងការទទួលខុសត្រូវនៃមុខងារសាធារណៈត្រូវបានផ្ទេរពី រដ្ឋាភិបាលកណ្ដាល ទៅរដ្ឋាភិបាលមូលដ្ឋាន សង្គមស៊ីវិល និង អង្គការមិនមែនរដ្ឋាភិបាលដទៃទៀត។

# ៣. វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា (ត)

- វិមជ្ឈការ និងវិសហមជ្ឈការក្នុងបរិបទកម្ពុជា

| វិមជ្ឈការ | វិសហមជ្ឈការ |
|---|---|
| គឺជាការដែលរាជរដ្ឋាភិបាលប្រគល់ឲ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធានដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់មូលដ្ឋាន ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនេះ។ | ជាការដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលផ្ទេរប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធានទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ននោះ។ |

# ៣. វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា (ត)



ដើម្បីជំរុញឲ្យការគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើឡើងតាមគោលការណ៍នៃរដ្ឋបាលឯកភាព សំដៅបង្កើតជំរុញ និងធ្វើឲ្យមានចីរភាពដល់ **ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**។

ទស្សនវិស័យនៃវិមជ្ឈការ
និងវិសហមជ្ឈការនៅកម្ពុជា

# ៤. ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានសមាសធាតុ៨៖



ភាពជាតំណាងសាធារណៈ




វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច



ស្វ័យភាពរបស់មូលដ្ឋាន





តម្លាភាព និងសុចរិតភាព



ការពិគ្រោះយោបល់ និងការចូលរួម



ការលើកស្ទួយសមធម៌



ការឆ្លើយតប និងគណនេយ្យភាព



ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន

# ៤. ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ត)

ភាពប្រទាក់ក្រឡាគ្នានៃសមាសធាតុទាំង៨



# ៥. ការរៀបចំឡើងវិញប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា




រាជធានី០១

ខេត្ត=២៤



ខណ្ឌ=១២

ក្រុង=២៦

ស្រុក=១៥៩



សង្កាត់=២៣៦

ឃុំ=១៤១០



សម្គាល់ ៖ ចំនួនភូមិសរុប = ១៤៣៨៣

## ៥. ការរៀបចំឡើងវិញប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ត)

### ក. ឋានៈផ្លូវច្បាប់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ

- កើតពីការបោះឆ្នោតសកល និងអសកល
- មានអាណត្តិ៥ឆ្នាំ
- ជានីតិបុគ្គល
- មានក្រុមប្រឹក្សាជាតំណាង
- មានសិទ្ធិអំណាច និងធនធានផ្ទាល់របស់ខ្លួន
- ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាច និងធនធានរបស់ខ្លួនដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## ខ. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

– សិទ្ធិអំណាចក្នុងការធ្វើសេចក្ដីសម្រេចខាងបញ្ញត្តិ និងខាងប្រតិបត្តិ
– សិទ្ធិអំណាចខាងបញ្ញត្តិតាមរយៈការដាក់ចេញដីកា
– សិទ្ធិអំណាចខាងប្រតិបត្តិតាមរយៈការធ្វើសេចក្ដីសម្រេចនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា
– ក្រុមប្រឹក្សានីមួយៗត្រូវធានាថា រាល់សេចក្ដីសម្រេចរបស់ខ្លួនត្រូវបានយកទៅអនុវត្ត។

# ៥. ការរៀបចំឡើងវិញប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ត)

## ខ. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា (ត)

- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាធ្វើសេចក្តីសម្រេចពាក់ព័ន្ធទៅនឹង៖
  – ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធាន
  – មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា
  – មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា
  – ផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល
  – គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
  – បញ្ហាហិរញ្ញវត្ថុផ្សេងទៀត

# ៥. ការរៀបចំឡើងវិញប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ត)

## ខ. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា (ត)

- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាធ្វើសេចក្តីសម្រេចពាក់ព័ន្ធទៅនឹង៖
  - ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាព និងបុគ្គលិក
  - ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ
  - ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជន និងការផ្សព្វផ្សាយព័ត៌មាន
  - កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋាន។

## គ. ការរៀបចំប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព៖
  - មានស្វ័យភាព
  - មានសមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាព
- ប្រភេទនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
  - រដ្ឋបាលមូលដ្ឋាន
    - » ពីរថ្នាក់៖ ស្រុក ឃុំ និងក្រុង សង្កាត់
    - » បីថ្នាក់៖ រាជធានី ខណ្ឌ សង្កាត់
  - រដ្ឋបាលតំបន់

# ៥. ការរៀបចំឡើងវិញប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ត)

## គ. ការរៀបចំប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ត)

- មូលហេតុនៃការរៀបចំឱ្យមានជារាជធានី ខណ្ឌ សង្កាត់ និងខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ គឺដើម្បី៖
  - ឲ្យមានលក្ខណៈស្របទៅនឹងស្ថានភាពខុសៗគ្នានៃប្រជាសាស្ត្រ សេដ្ឋកិច្ច សង្គម និងតម្រូវការនៃតំបន់ទីប្រជុំជន និងតំបន់ជនបទ
  - ឲ្យមានភាពងាយស្រួលក្នុងការពិចារណាអំពីការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធ ក៏ដូចជាការផ្ទេរមុខងារ និងធនធានពីថ្នាក់ជាតិ និងការបម្រើសេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅមូលដ្ឋាន

# ៥. ការរៀបចំឡើងវិញប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ត)

## គ. ការរៀបចំប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ( ត )

- រដ្ឋបាលថ្នាក់ក្រោមជាតិមានមុខងារ និងធនធានរបស់ខ្លួន ដែលរដ្ឋបាលនីមួយៗមានឆន្ទានុសិទ្ធិក្នុងការគ្រប់គ្រង និងចាត់ចែងមុខងារ និងធនធានទាំងនោះស្របតាមលិខិតបទដ្ឋានជាធរមាន
- ប្រភេទនៃមុខងារ៖ **មុខងារជាជម្រើស** **និងមុខងារជាកាតព្វកិច្ច**
- មុខងារទទួលបានតាមរយៈការផ្ទេរពីថ្នាក់ជាតិ
- ការផ្ទេរមុខងារទាំងនេះត្រូវផ្សាភ្ជាប់ជាមួយនូវធនធានចាំបាច់ និងការតាមដាន គាំទ្រ

# ៥. ការរៀបចំឡើងវិញប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ត)

## គ. ការរៀបចំប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ(ត)

- ប្រភពចំណូលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ មានបីប្រភេទ៖
  - ចំណូលពីប្រភពនៅមូលដ្ឋាន
  - ចំណូលពីប្រភពនៅថ្នាក់ជាតិ
  - ចំណូលពីប្រភពផ្សេងៗទៀត។

# ៥. ការរៀបចំឡើងវិញប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ត)

## ឃ. ខ្សែគណនេយ្យភាព

**ទីមួយ** គឺជាគណនេយ្យភាពពីលើចុះក្រោម (គណនេយ្យភាពចំពោះប្រជាពលរដ្ឋ)



**ទីពីរ** គឺជាគណនេយ្យភាពពីក្រោមឡើងលើ(គណនេយ្យភាព ចំពោះថ្នាក់ជាតិ)

**ទីបី** គឺជាគណនេយ្យភាពផ្ទៃក្នុងនៅក្នុងក្របខ័ណ្ឌនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ

## ៦. ទំនាក់ទំនងរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ទំនាក់ទំនងរវាងក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ៖

- ក្រសួង ស្ថាប័នថ្នាក់ជាតិ៖
  - កំណត់អំពីស្តង់ដារជាតិសម្រាប់អនុវត្ត
  - ពិនិត្យនីត្យានុកូលភាពទៅលើការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់
  - តាមដាន ត្រួតពិនិត្យ និងគាំទ្រ
- រដ្ឋបាលថ្នាក់ក្រោមជាតិ៖
  - គោរពតាមស្តង់ដារជាតិ
  - មានគណនេយ្យភាពចំពោះ ថ្នាក់ជាតិ ក្នុងការអនុវត្តមុខងារ ទទួលបានការផ្ទេរ។



សូមអរគុណ!